# សុន្ទរកថាបើក
# ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ អគ្គនាយករង ប.ស.ស.
# វេទិកាឈ្វេងយល់អំពីអត្ថប្រយោជន៍គាំពារសង្គមក្នុងវិស័យ
# កសិឧស្សាហកម្មចេក និងកៅស៊ូ ប្រកបដោយបរិយាបន្ន

ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥ វេលាម៉ោង ៨:០០នាទីព្រឹក

នៅសណ្ឋាគារ ហ៊ារប៊ុន្នី ខេត្តក្រចេះ

***សូមគោរព!***

- **លោកជំទាវ ខាំ សុភាព** អភិបាលរងខេត្តនៃគណៈអភិបាលខេត្តក្រចេះ
- **លោកស្រី ម៉ាន អាស៊ីសាស់** តំណាងអង្គការ OXFAM ប្រចាំនៅកម្ពុជា
- **លោកស្រី លុយ ធារី** ប្រធានផ្នែកកម្មវិធីនៃអង្គការគណៈកម្មាធិការ សហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
- ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន សមាគមនិយោជក សហជីព អង្គការជាតិ-អន្តរជាតិ
- លោក លោកស្រី សមាជិក សមាជិកា នៃវេទិកាថ្នាក់តំបន់ ជាទីមេត្រី!!!

ថ្ងៃនេះ តាងនាម **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ ដោយបានចូលរួមជាអធិបតីក្នុងវេទិកា "**ឈ្វេងយល់អំពីអត្ថប្រយោជន៍គាំពារសង្គមក្នុងវិស័យកសិឧស្សាហកម្មចេក និងកៅស៊ូប្រកបដោយបរិយាបន្ន**" ដែលសហការរៀបចំដោយ បេឡាជាតិសន្តិសុខសង្គមនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការ OXFAM នាពេលនេះ។

ខ្ញុំសូមថ្លែងអំណរគុណដល់អង្គការ OXFAM និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ដែលបានសហការរៀបចំវេទិកាថ្នាក់តំបន់នេះឡើង ជាពិសេស **លោកស្រី ភាណ សោភ័ណ** នាយិកាអង្គការ OXFAM និងក្រុមការងាររបស់អង្គការ OXFAM ដែលបានជួយគាំទ្រដល់ ប.ស.ស. កន្លងមក និងក៏សូមអរគុណដល់ **លោកជំទាវ ខាំ សុភាព** អភិបាលរងនៃគណៈអភិបាលខេត្តក្រចេះ សមាជិក សមាជិកា នៃវេទិកាថ្នាក់តំបន់ទាំងមូល ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងវេទិកាដ៏មានសារសំខាន់នេះ ដែលស្ថិតនៅក្រោមប្រធានបទ "**គាំពារសង្គម ដើម្បីអន្តរកាលយុត្តិធម៌ និងសកម្មភាពបរិស្ថាននៅកម្ពុជា**"។

ខ្ញុំសូមយកឱកាសនេះ សូមសំដែងការកោតសរសើរចំពោះអង្គការ OXFAM ដែលបានខិតខំប្រឹងប្រែងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូក្នុងការអនុវត្តគម្រោងគាំពារសង្គម រួមមាន គម្រោងស្ដីពី "ការធ្វើឱ្យប្រសើរឡើងដល់គាំពារសង្គម និងសិទ្ធិការងារសម្រាប់កម្មករជាស្ត្រីក្នុងវិស័យកសិ-ស្បៀងអាហារ" ក្រោមមូលនិធិរាជរដ្ឋាភិបាលបែលហ្សិក (DGD) និងគម្រោងស្ដីពី "គាំពារសង្គមប្រកបដោយបរិយាបន្នដែលឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែង របស់កម្មករនិយោជិតក្នុងវិស័យកាត់ដេរ" (INSPIRE) ក្រោមជំនួយរបស់មូលនិធិ Laudes Foundation និងគម្រោងពាក់ព័ន្ធផ្សេងៗទៀត ដើម្បីរួមចំណែកក្នុងការពង្រីកវិសាលភាពគ្របដណ្ដប់របបសន្តិសុខសង្គមនៅកម្ពុជា ឱ្យកាន់តែទូលំទូលាយ និងល្អប្រសើរបន្ថែមទៀត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**!

ដើម្បីធានាបាននូវការអនុវត្តការងារខាងលើនេះ ប្រកបដោយភាពជោគជ័យ ប.ស.ស. និងអង្គការ OXFAM បានសហការរៀបចំវេទិកាថ្នាក់តំបន់នេះឡើង ក្នុងគោលបំណងសំខាន់ៗដូចខាងក្រោម៖

ក. **បង្កើនការផ្សព្វផ្សាយអំពី អត្ថប្រយោជន៍ សិទ្ធិការងារ និងសិទ្ធិទទួលបាន កិច្ចគាំពារសង្គម និងគោលការណ៍សុវត្ថិភាពនៅកន្លែងធ្វើការ** សម្រាប់កម្មករនិយោជិតនៅក្នុងវិស័យកសិ-ឧស្សាហកម្មចម្ការចេក និងកៅស៊ូ

ខ. **លើកកម្ពស់ការចូលរួមរបស់ភាគីពាក់ព័ន្ធ និងជំរុញការយកចិត្តទុកដាក់ដោះស្រាយបញ្ហាប្រឈម និងតម្រូវការកិច្ចគាំពារសង្គម និងសម្ភារៈសុវត្ថិភាព**អំឡុងពេលបំពេញការងាររបស់កម្មករនិយោជិតនៅក្នុងវិស័យចម្ការចេក និងកៅស៊ូ។

គ. **ផ្ដល់ឱកាសដល់កម្មករនិយោជិតនៅក្នុងវិស័យចម្ការចេក និងកៅស៊ូលើកឡើងនូវបញ្ហាប្រឈម ដល់អ្នកធ្វើការសម្រេចចិត្ត និងភាគីពាក់ព័ន្ធ**ដើម្បីចូលរួមផ្ដល់ដំណោះស្រាយដល់កម្មករនិយោជិត

ឃ. **ចែករំលែកអំពីការអនុវត្តន៍ល្អៗ និងតម្រូវការ**អនុលោមភាព EUDR ក្នុងវិស័យកសិឧស្សាហកម្ម កៅស៊ូ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ជាមួយគ្នានេះដែរ ការអនុវត្តគម្រោងខាងលើនេះ ជាផ្នែកមួយដ៏សំខាន់ ក្នុងការរួមចំណែកអនុវត្តសកម្មភាពឆ្ពោះទៅការកសាងប្រព័ន្ធគាំពារសង្គម ដែលអនុលោមតាមក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥ និងឆ្នាំ២០២៤-២០៣៥ យុទ្ធសាស្ត្រជាតិស្ដីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨ ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្ដប់សុខភាពជាសកលនៅកម្ពុជាឆ្នាំ២០២៤-២០៣៥ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់លើការលើកកម្ពស់សុខុមាលភាព និងជីវភាពរបស់ប្រជាពលរដ្ឋ ដោយដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គម ជាដំណាក់កាលស្របតាមការវិវឌ្ឍនៃសេដ្ឋកិច្ច និងសង្គម។ ដើម្បីអនុវត្តរបបសន្តិសុខសង្គមមានលក្ខណៈទូលំទូលាយ និងមានការគ្របដណ្ដប់គ្រប់ជ្រុងជ្រោយ រាជរដ្ឋាភិបាលក៏បានបង្កើតច្បាប់ថ្មីស្ដីពី របបសន្តិសុខសង្គម ដោយប្រកាសឱ្យប្រើនៅឆ្នាំ២០១៩ ដែលមានវិសាលភាពអនុវត្តចំពោះបុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកដែលធ្វើការតាមផ្លូវអាកាស និងនាវិកសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ និងបុគ្គលស្វ័យនិយោជន៍។

សូមបញ្ជាក់ផងដែរថា បេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានដាក់ឱ្យមានសាខាខេត្ត/ខណ្ឌចំនួន **៣៨ទីតាំង** ទូទាំងប្រទេស ហើយថ្មីៗនេះ ប.ស.ស. ក៏បានពង្រីកទីតាំងផ្ដល់សេវារបស់ខ្លួននៅតាមផ្សារទំនើប រួមមាន ផ្សារអ៊ីអន ១, ២, និង៣ ផងដែរ ក្នុងគោលបំណងជួយសម្រួល និងធ្វើយ៉ាងណាឱ្យបងប្អូនកម្មករនិយោជិត ទទួលបានការយកចិត្តទុកដាក់ នៅពេលបងប្អូនកម្មករនិយោជិតជួបប្រទះនូវបញ្ហាសុខភាព គ្រោះថ្នាក់ការងារ និងជាពិសេសពេលមានតម្រូវការផ្សេងៗ ពី ប.ស.ស. ដូចជា ដាក់ឯកសារទាមទារអត្ថប្រយោជន៍សំណងទូទាត់ ធ្វើបណ្ណសមាជិក ប.ស.ស. ជាដើម។

ដោយឡែកសម្រាប់ សាខា ប.ស.ស. ខេត្តក្រចេះ បានបង្កើត និងចាប់ផ្ដើមដំណើរការនៅក្នុងឆ្នាំ២០១០ ដែលមានថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកសរុបចំនួន **១៨រូប** ដើម្បីរង់ចាំផ្ដល់សេវាជូនដល់សមាជិក ប.ស.ស. និងសាធារណៈជនក្នុងខេត្តក្រចេះ។ ក្នុងនោះសាខា ប.ស.ស. ខេត្តក្រចេះ មានទីតាំងស្ថិតនៅផ្លូវលេខជាតិលេខ៧ ភូមិអូរឫស្សី១ សង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ គឺក្នុងគោលបំណងជួយសម្រួលដល់បងប្អូនកម្មករនិយោជិត កុំឱ្យពិបាកក្នុងការធ្វើដំណើរឆ្ងាយដើម្បីមកទទួលសេវាផ្សេងៗពី ប.ស.ស.។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមរាយការណ៍ជូននូវវឌ្ឍនភាពនៃការអនុវត្តរបបសន្តិសុខសង្គម ជូនអង្គពិធីដូចតទៅ៖

**១. ការអនុវត្តរបបសន្តិសុខសង្គម**

- ផ្នែកហានិភ័យការងារបានចាប់ផ្ដើមអនុវត្តនៅឆ្នាំ២០០៨ សម្រាប់វិស័យឯកជន និងនៅឆ្នាំ២០២១ សម្រាប់វិស័យសាធារណៈ
- ផ្នែកថែទាំសុខភាពបានចាប់ផ្ដើមអនុវត្តនៅឆ្នាំ២០១៦ សម្រាប់វិស័យឯកជន និងនៅឆ្នាំ២០១៨ សម្រាប់វិស័យសាធារណៈ
- ផ្នែកប្រាក់សោធនបានចាប់ផ្ដើមអនុវត្តនៅឆ្នាំ២០២២ សម្រាប់វិស័យឯកជន
- ផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. បានដាក់ឱ្យអនុវត្តនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**២. ការងារចុះបញ្ជិកា៖ គិតត្រឹមខែកក្កដា ឆ្នាំ២០២៥**

ប.ស.ស. មានសមាជិកសរុបចំនួនជាង **៣លាន ២ម៉ឺននាក់** ក្នុងនោះ៖

- សម្រាប់វិស័យសាធារណៈ មានចំនួនជាង **៥២ម៉ឺន** ក្នុងនោះខេត្តក្រចេះ មានចំនួនជាង **៩៣ពាន់ ៥រយនាក់**
- សម្រាប់វិស័យឯកជន មានចំនួនជាង **១លាន ៩៦ម៉ឺននាក់** ក្នុងនោះខេត្តក្រចេះ មានចំនួនជាង **៨៣ពាន់ ៥រយនាក់**
- បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស.
  - ផ្នែកថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍ មានចំនួនជាង **៥០ម៉ឺន ៩ពាន់នាក់** ក្នុងនោះខេត្តក្រចេះ មានចំនួនជាង **៥ពាន់ ៤រយនាក់**
  - ផ្នែកថែទាំសុខភាពសម្រាប់អ្នកក្នុងបន្ទុកសមាជិក ប.ស.ស. មានចំនួនជាង **២១ម៉ឺន ២រយនាក់** ក្នុងនោះខេត្តក្រចេះ មានចំនួនជាង **៤ពាន់ ៣រយនាក់**។

**៣. អំពីមូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀង ជាមួយបេឡាជាតិសន្តិសុខសង្គម ៖ គិតត្រឹមខែកក្កដា ឆ្នាំ២០២៥**

ដើម្បីធ្វើប្រតិបត្តិការក្នុងការផ្តល់សេវាដល់សមាជិក ប.ស.ស. ឱ្យឆាប់រហ័ស និងទាន់ពេលវេលា ប.ស.ស. បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល **ចំនួន ១ ៦០១៖**

- មូលដ្ឋានសុខាភិបាលសាធារណៈថ្នាក់ជាតិ **ចំនួន ១៤**
- មន្ទីរពេទ្យបង្អែក **ចំនួន ១២៦**
- មណ្ឌលសុខភាព **ចំនួន ១ ២៩៦**
- មូលដ្ឋានសុខាភិបាលឯកជន **ចំនួន ១៦៥**។

ដោយឡែកខេត្តរតនគិរី **ប.ស.ស.** បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលសាធារណៈ **ចំនួន ៤៥**។

**អង្គទេវិកា ជាទីមេត្រី!**

តាមរយៈវេទិកាប្រចាំឆ្នាំថ្នាក់តំបន់នេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកាទាំងអស់ នឹងទទួលបាននូវ**ពុទ្ធិ ជាតុចូល និងវិធីសាស្ត្រសំខាន់ៗ ដើម្បីជាគន្លឹះក្នុងការរៀបចំនូវយុទ្ធសាស្ត្រ និងផែនការការងារបន្ទាប់ សម្រាប់អនុវត្តការងារប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ ដែលជាការរួមចំណែកលើកកម្ពស់ និងការពង្រីករបបសន្តិសុខសង្គមកម្ពុជា ទៅដល់ប្រជាជនគោលដៅឱ្យកាន់តែទូលំទូលាយ និងឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល**។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** សូមប្រកបដោយសុខភាពល្អបរិបូរណ៍ និងទទួលបានជោគជ័យគ្រប់ភារកិច្ច និងសូមឱ្យវេទិកាប្រចាំឆ្នាំថ្នាក់តំបន់នេះ ប្រារព្ធទៅប្រកបដោយជោគជ័យ និងទទួលបានផ្លែផ្កាដូចការរំពឹងទុក។

ខ្ញុំសូមប្រកាសបើក **វេទិកាថ្នាក់តំបន់ភូមិភាគឦសាន្តស្តីពី គាំពារសង្គមដើម្បីអន្តរកាលយុត្តិធម៌ និងសកម្មភាពបរិស្ថាននៅកម្ពុជា** ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**